# ស្ថានភាពអតិផរណានៅខែមករា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែមករា ឆ្នាំ២០១៨ បានកើនឡើងក្នុងអត្រា **0,9%** ធៀបនឹងខែមុន និងកើនឡើង **២,0%** បើធៀបនឹង១២ខែមុន។

ក្នុងខែមករានេះ សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនមានការកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែធ្នូ ឆ្នាំ២០១៧កន្លងទៅ ដូចជា សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃការដឹកជញ្ជូន, សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, និងសន្ទស្សន៍ថ្លៃទំនិញនិងសេវាកម្មផ្សេងៗ។ រីឯសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងមានការថយចុះបន្តិច ដោយសារការថយចុះនៃថ្លៃសាច់ (សាច់គោថយចុះ 0,៥%, សាច់មាន់ 0,៣% និងសាច់ទា 0,១%) ត្រីស្រស់ថយចុះ 0,២% បន្លែថយចុះ 0,៣% និងផ្លែឈើថយចុះ 0,៥%។

បើធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើននៅតែបន្តកើនឡើងដូចជាសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, សន្ទស្សន៍ថ្លៃដឹកជញ្ជូន, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង និងសន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត។ តាមការសង្កេត សន្ទស្សន៍ថ្លៃម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងមាននិន្នាការថមថយកំណើនចាប់តាំងពីខែមេសា ឆ្នាំ២០១៧កន្លងមក។ ក្នុងខែមករានេះ សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងបានកើនឡើងក្នុងអត្រាត្រឹមតែ ១,៥% ទាបជាងកំណើនជាមធ្យមក្នុងរយៈពេល ២ឆ្នាំចុងក្រោយ (២០១៦-២០១៧) ដែលមានអត្រា ៤,៥% ដែលការថមថយកំណើននេះ មួយផ្នែកគឺបណ្ដាលមកពីការថមថយកំណើននៃ ថ្លៃសាច់ស្រស់, ត្រីស្រស់, បន្លែ និងផ្លែឈើជាដើម។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | **ធៀបនឹងខែមុន** | **ធៀបនឹង១ឆ្នាំមុន** |
| **មុខទំនិញគ្រប់មុខ** | **+0,9** | **+២,0** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | -0,១ | +១,៥ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +0,៤ | +0,៤ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +0,៣ | +១,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | 0,0 | +១,៥ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +0,១ | +0,២ |
| ៦-សុខាភិបាល | -0,១ | +១,១ |
| ៧-ការដឹកជញ្ជូន | +0,៦ | +៣,៨ |
| ៨-គមនាគមន៍ | -0,១ | -១,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | -0,២ | -១,៦ |
| ១0-ការសិក្សា | 0,0 | -0,៧ |
| ១១-ភោជនីយដ្ឋាន | +0,៧ | +៦,៧ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +0,៣ | +៣,0 |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៧ | | ២០១៨ | ២០១៧ | | ២០១៨ |
| | វិច្ឆិកា | ធ្នូ | មករា | វិច្ឆិកា | ធ្នូ | មករា |
| អង្ករ | +០,៣ | +០,១ | +០,១ | +២,០ | +១,៦ | +២,៣ |
| សាច់គោ | +០,៤ | +០,៨ | -០,៥ | +២,៥ | +៣,០ | +២,២ |
| សាច់មាន់ | ០,០ | -០,៦ | -០,៣ | +១,២ | +០,៣ | -០,៩ |
| សាច់ទា | +០,៣ | +០,៣ | -០,១ | +០,៩ | +០,៦ | +០,៤ |
| សាច់ជ្រូក | +០,៤ | -០,៦ | +០,៦ | +១,០ | -០,៣ | -០,២ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +១,២ | ០,០ | -០,១ | +៤,៩ | +៤,៥ | +៤,៣ |
| ក្នុងនោះត្រីស្រស់ | +១,៤ | ០,០ | -០,២ | +៥,២ | +៤,៩ | +៤,៦ |
| ផ្លែឈើ | -០,៣ | +០,៨ | -០,៥ | +០,៨ | +១,០ | -០,១ |
| ផ្លែឈើស្រស់ | -០,៤ | +១,០ | -០,៥ | ០,០ | +០,៣ | -០,៨ |
| បន្លែ | ០,០ | +០,៦ | -០,៣ | -១,៣ | -០,៩ | -១,៤ |
| បន្លែជាស្លឹក | +១,៣ | +១,៦ | -១,២ | -១,៧ | -០,៧ | -១,៧ |
| បន្លែជាផ្លែ | -១,៥ | -០,១ | +១,៤ | -៤,៥ | -៤,០ | -៣,៨ |

## ២/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | | | | | | | | | | ២០១៨ |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា |
| ប្រទេសកម្ពុជា | 4.4 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.6 | 2.7 | 2.1 | 2.3 | 2.2 | 2.0 |
| ប្រទេសវៀតណាម | 5.2 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 | 3.4 | 3.4 | 3.0 | 2.6 | 2.6 | 2.7 |
| ប្រទេសថៃ | 1.6 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 | 0.3 | 0.9 | 0.9 | 0.99 | 0.78 | 0.68 |
| ប្រទេសម៉ាឡេស៊ី | 3.2 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 | 3.7 | 4.3 | 3.7 | 3.4 | 3.5 | 2.7 |
| ប្រទេសឥណ្ឌូនេស៊ី | 3.5 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 | 3.8 | 3.7 | 3.6 | 3.3 | 3.6 | 3.3 |
| ប្រទេសហ្វីលីពីន | 2.7 | 3.3 | 3.4 | 3.4 | 3.1 | 2.8 | 2.8 | 3.1 | 3.4 | 3.5 | 3.3 | 3.3 | 4.0 |
| ប្រទេសចិន | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 | 1.8 | 1.6 | 1.9 | 1.7 | 1.8 | 1.5 |
| ប្រទេសកូរ៉េខាងត្បូង | 2.0 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 | 2.6 | 2.1 | 1.8 | 1.3 | 1.5 | 1.0 |
| ប្រទេសជប៉ុន | 0.4 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 | 0.7 | 0.7 | 0.2 | 0.6 | 1.0 | 1.4 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**កំណត់សម្គាល់**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្រ្ត (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*